**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

លេខ៖ បព ៤១/២០២៥ កបទ.សអ

សេចក្តីប្រកាសព័ត៌មាន

## ការបង្កើតការិយាល័យទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍នៃប្រទេសលុចសំបួ នៅព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលលុចសំបួ គ្រោងនឹងបើកការិយាល័យ ទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍នៃប្រទេសលុចសំបួ ( Luxemburg Development Cooperation Agency-Lux-Development S.A. ) នៅព្រះរាជាណាចក្រកម្ពុជា។

គម្រោងបង្កើតការិយាល័យទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍នេះ ត្រូវបានផ្តួចផ្តើមឡើងក្នុងឱកាសព្រះរាជទស្សនកិច្ចរបស់ **ព្រះអង្គម្ចាស់ Grand Duke Guillaume** ដែលពេលនោះព្រះអង្គជារជ្ជទាយាទនៃប្រទេសលុចសំបួ និងបច្ចុប្បន្នជាព្រះមហាក្សត្រលុចសំបួ តាមរយៈការចុះហត្ថលេខាលើកិច្ចព្រមព្រៀងកិច្ចសហប្រតិបត្តិការទូទៅរវាងរាជរដ្ឋាភិបាលកម្ពុជា និងរាជរដ្ឋាភិបាលលុចសំបួ កាលពីថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៥ នៅព្រះរាជាណាចក្រកម្ពុជា។ ការិយាល័យនេះ នឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការទ្វេភាគីរវាងប្រទេសទាំងពីរ ជាពិសេសចូលរួមចំណែកយ៉ាងសំខាន់ដល់ការអភិវឌ្ឍសង្គមសេដ្ឋកិច្ចនៅកម្ពុជា តាមរយៈគំនិតផ្តួចផ្តើម និងគម្រោងការអភិវឌ្ឍន៍នានា។

វត្តមាននៃការិយាល័យអភិវឌ្ឍន៍ខាងលើ ឆ្លុះបញ្ចាំងអំពីការវិវត្តជាវិជ្ជមាននៃទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរកាន់តែខ្ពស់មួយកម្រិតទៀត និងសបញ្ជាក់អំពីការប្តេជ្ញាចិត្តរបស់កម្ពុជានិងលុចសំបួ ក្នុងការអភិវឌ្ឍភាពជាដៃគូឱ្យកាន់តែរឹងមាំនិងយូរអង្វែង។ ប្រទេសទាំងពីរនឹងផ្តោតកិច្ចសហប្រតិបត្តិការលើវិស័យគន្លឹះ រួមមានការអភិវឌ្ឍសេដ្ឋកិច្ចនិងការកាត់បន្ថយភាពក្រីក្រ ការអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សុខភាពនិងការគាំពារសង្គម ការអភិវឌ្ឍប្រកបដោយចីរភាពបរិស្ថាន ព្រមទាំងកិច្ចសហប្រតិបត្តិការក្នុងការបោសសម្អាតមីននិងសន្តិសុខ និងការអភិវឌ្ឍមូលដ្ឋាន។

ជាថ្មីម្តងទៀត រាជរដ្ឋាភិបាលកម្ពុជា និងរាជរដ្ឋាភិបាលលុចសំបួ ស្វាគមន៍នូវកិច្ចសហប្រតិបត្តិការដំណាក់កាលវិវត្តនៃទំនាក់ទំនងទ្វេភាគីជាវិជ្ជមានថ្មីនេះ និងត្រៀមខ្លួនរួចរាល់ក្នុងការជំរុញកិច្ចសហការរួមគ្នាយ៉ាងជិតស្និទ្ធ ក្នុងគោលដៅធ្វើអោយដំណើរការនៃការបើកការិយាល័យទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍នៃប្រទេសលុចសំបួ នៅព្រះរាជាណាចក្រកម្ពុជាឱ្យបានឆាប់ សំដៅលើកកម្ពស់ទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការទ្វេភាគីឱ្យកាន់តែល្អប្រសើរ ដើម្បីជាប្រយោជន៍សម្រាប់ប្រជាជាតិ និងប្រជាជននៃប្រទេសទាំងពីរ។

ថ្ងៃពុធ ១កើត ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ពុទ្ធសករាជ ២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២២ ខែតុលា ឆ្នាំ២០២៥

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល: mfaic@mfaic.gov.kh

KINGDOM OF CAMBODIA
NATION RELIGION KING

MINISTRY OF FOREIGN AFFAIRS
AND INTERNATIONAL COOPERATION

No. PR. 41/2025 MFA.IC

PRESS RELEASE

## Establishment of an Office of the Luxembourg Development Cooperation Agency in the Kingdom of Cambodia

The Government of the Grand Duchy of Luxembourg will open an office of the Luxembourg Development Cooperation Agency, Lux-Development S.A., in the Kingdom of Cambodia.

The establishment of this office was initiated on the occasion of the official visit of His Royal Highness **Grand Duke Guillaume**, then Crown Prince and now Grand Duke of Luxembourg, and in conjunction with the signing of the General Cooperation Agreement between the two governments on 31 March 2025 in the Kingdom of Cambodia. The Lux-Development Office will play an important role in strengthening and expanding bilateral cooperation between the two countries, notably by contributing significantly to the socio-economic development of Cambodia through various development initiatives and projects.

The presence of the above development office reflects the positive evolution of relations and cooperation between the two countries at a higher level and reaffirms the commitment of Cambodia and Luxembourg to develop a stronger and more lasting partnership. The two countries will focus on cooperation in key areas, including economic development and poverty reduction, education and vocational training, health and social protection, sustainable development and environmental protection, as well as cooperation in humanitarian demining and community security, thereby contributing to stability and local development.

Once again, the Royal Government of Cambodia and the Government of the Grand Duchy of Luxembourg welcome this new phase of cooperation and express their readiness to work closely together to accelerate the process of opening the Lux-Development office in Cambodia as soon as possible, with the aim of promoting closer bilateral relations and enhanced cooperation for the benefit of the nations and peoples of both countries.

Phnom Penh, 22 October 2025

Address : N° 3, Samdech HUN Sen Street,
Sangkat Tonle Bassac, Khan Chamkarmon
Phnom Penh, Kingdom of Cambodia

Tel : (855) 23 216 122
Fax : (855) 23 216 141, 023 213 341
Email : mfaic@mfaic.gov.kh

ROYAUME DU CAMBODGE
NATION RELIGION ROI

MINISTÈRE DES AFFAIRES ÉTRANGÈRES
ET DE LA COOPÉRATION INTERNATIONALE

No. PR. 41/2025 MAE.CI

COMMUNIQUÉ DE PRESSE

# Établissement d'un bureau de l'Agence luxembourgeoise de coopération au développement au Royaume du Cambodge

Le Gouvernement du Grand-Duché de Luxembourg ouvrira un bureau de l'Agence luxembourgeoise de coopération au développement, Lux-Development S.A., au Royaume du Cambodge.

Le projet d'établissement de ce bureau a été initié à l'occasion de la visite officielle de **Son Altesse Royale le Grand-Duc Guillaume**, alors Prince héritier et aujourd'hui Grand-Duc de Luxembourg, et de la signature de l'Accord général de coopération entre les deux gouvernements, le 31 mars 2025, au Royaume du Cambodge. Le bureau Lux-Development constituera une structure opérationnelle clé pour le renforcement des projets de développement et la coordination des diverses initiatives bilatérales sur le terrain. Il facilitera la planification, la mise en œuvre et le suivi des programmes de coopération luxembourgeois au Cambodge.

L'ouverture de ce bureau illustre le renforcement des relations et de la coopération bilatérale entre les deux pays, et témoigne de la volonté commune du Cambodge et du Luxembourg de consolider un partenariat durable et solide. Les deux pays continueront à collaborer dans plusieurs secteurs clés, notamment le développement économique et la réduction de la pauvreté, l'éducation et la formation professionnelle, la santé et la protection sociale, le développement durable et la protection de l'environnement ainsi que la coopération dans le domaine du déminage humanitaire et de la sécurité communautaire, contribuant à la stabilité et au développement local.

Le Gouvernement royal du Cambodge et le Gouvernement du Grand-Duché de Luxembourg se félicitent de cette nouvelle phase de coopération, et réaffirment leur engagement à travailler en étroite collaboration pour l'ouverture de ce bureau de Lux-Development au Cambodge, dans le but de promouvoir davantage les relations d'amitié et de coopération bilatérale, au bénéfice des peuples des deux nations.

Phnom Penh, le 22 octobre 2025

Adresse : N° 3, Rue Samdech HUN Sen,
Sangkat Tonle Bassac, Khan Chamkarmon
Phnom Penh, Royaume du Cambodge

Tél : (855) 23 216 122
Fax : (855) 23 216 141, 023 213 341
Email : mfaic@mfaic.gov.kh